ផែនការបន្ទាន់ដែលកំពុងដំណើរការនៅកម្ពុជា (The Emergency Plan at Work)

បញ្ហាប្រឈមចំពោះការអនុវត្តផែនការបន្ទាន់

ប្រទេសកម្ពុជាទើបតែរួចចាកផុតពីសង្គ្រាម ហើយការនេះធ្វើអោយមានការពិបាកច្រើនដល់ការពង្រីកសកម្មភាពការងារ ។ ឧបសគ្គធំៗដល់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៏រួមមានៈ

- មានករណីប្រើថ្នាំញៀននិងការរួមភេទដោយមិនមានប្រើស្រោមអនាម័យច្រើន ។
- ភាពក្រីក្រដែលជំរុញអោយមនុស្សសុខចិត្តប្រកបរបរពេស្យាចារ ការរួមស៊ិចដើម្បីរកប្រាក់ចិញ្ចឹមជីវិត និង អំពើពុករលួយ
- ឧបសគ្គក្នុងការទទួលបានសេវាថែទាំ ព្យាបាល និង ការពារ ដែលរួមមានទាំងចំងាយផ្លូវឆ្ងាយក្នុងការធ្វើដំណើរទៅទីកន្លែងផ្តល់សេវា ការខ្វះខាតថវិកា ការមិនសូវមានយាន្តជំនិះនិងហេដ្ឋារចនាសម្ព័ន្ធ ហើយនិងឧបសគ្គផ្នែកភូមិសាស្រ្ត
- ប្រាក់ខែរបស់បុគ្គលិក្នុងវិស័យសុខាភិបាលមានកំរិតទាប ។
- គ្រូពេទ្យមានជំនាញនិងសមត្ថភាពនៅមានកំរិត ។

បន្ថយការមាក់ងាយនិងការរើសអើងប្រឆាំងនឹងអ្នកផ្ទុកមេរោគអេដស៏/អ្នកជំងឺអេដស៏

ដោយមានការជួយពីផែនការបន្ទាន់ អង្គការ ផែកនៅកម្ពុជា (Pact-Cambodia) ដែលជាអង្គការ មិនមែនរដ្ឋាភិបាលនៅកម្ពុជា ហើយនិងបណ្តាញអ្នកជំងឺអេដស៏នៅកម្ពុជា កំពុងតែដំណើរការ *គំរោងស្តីពីការឆ្លើយតបរបស់សហគមន៏ដើម្បីបន្ថយការមាក់ងាយនិងការរើសអើងប្រឆាំងនឹងអ្នកផ្ទុកមេរោគអេដស៏/ជំងឺ អេដស៏* ។ គំរោងនេះប្រើប្រាស់វេទិការនៅតាមសហគមន៏ដើម្បីអប់រំសមាជិកសហគមន៏អំពីមេរោគ/ជំងឺ អេដស៏ ។ ឡូន ខឿន មានអាយុ ៣៥ ឆ្នាំ មកពីភូមិតា នុក មានផ្ទុកមេរោគអេដស៏ ។ គាត់បានមើលឃើញ

ពីផលល្អនៃវេទិកាការតាមសហគមន៍ដែលរៀបចំឡើងដោយមានការឧបត្ថម្ភពី PEPFAR ។ ក្រោយពីប្តីរបស់គាត់បានស្លាប់ដោយសារជំងឺដែលទាក់ទងនឹងជំងឺអេដស៍កាលពី ៣ឆ្នាំមុន ឡូន ខឿននិងប្អូនស្រីរបស់គាត់បានប្រឈមមុខនឹងការមាក់ងាយហើយនិងការរើសអើងពីសមាជិកសហគមន៍ ដោយសារឡូន ខឿនមានផ្ទុកមេរោគអេដស៍ ។ អ្នកជិតខាងខ្លាចមិនហ៊ានទិញឪឡឹកឬអាហារពីឡូន ខឿនទេ ។ ដូច្នេះ មុខរបរលក់បាយរបស់ឡូន ខឿនត្រូវជួបការពិបាក ។ ឡូន ខឿននិងសមាជិកដទៃទៀតក្នុងសហគមន៍បានចូលរួមក្នុងវេទិការសហគមន៍ក្នុងភូមិរបស់គាត់ ។ នៅក្នុងវេទិការនោះ គេមានពិភាក្សាពីការយល់ដឹងពីជំងឺអេដស៍ ការមាក់ងាយនិងការរើសអើង ច្បាប់ស្តីពីជំងឺអេដស៍ ការស្វែងរកជំនួយសំរាប់អ្នកផ្ទុកមេរោគអេដស៍/អ្នកមានជំងឺអេដស៍ ពីសហគមន៍ អាជ្ញាធមិមូលដ្ឋាន គ្រូពេទ្យ និង អ្នកដឹកនាំក្នុងការបញ្ចេញមតិ ។ បន្ទាប់ពីបានចូលរួមនៅក្នុងវេទិការមក អ្នករស់នៅក្នុងសហគមន៍បានផ្លាស់ប្តូរអាកប្បកិរិយារបស់គេ ហើយបែរមកគាំទ្រ អ្នកជំងឺអេដស៍ ។ គេចាប់មានការរាប់អានឡូន ខឿនច្រើន ដោយទិញអាហារនិងរបស់របរពីគាត់ ទៅលេង ផ្ទះគាត់លេងជាមួយកូនគាត់ និងហូបបាយជាមួយគាត់ ។ នៅពេលនេះ គាត់អាចបន្តមុខរបររបស់គាត់និងអាចចិញ្ចឹមកូនស្រីរបស់គាត់បាន ។

ផល្លី: រឿងរបស់ស្ត្រីដ៏ក្លាហានម្នាក់

នៅពេលក្រុមអ្នកចុះផ្តល់ការថែទាំនៅតាមផ្ទះបានចុះទៅមើលគាត់ជាលើកដំបូងក្នុងខែធ្នូ ឆ្នាំ ១៩៩៩ នាងផល្លីមានការពិបាកចិត្តហើយមានជំងឺដែលបណ្តាលមកពីមេរោគអេដស៍ដែលមាននៅក្នុងខ្លួនគាត់ ។ នៅ ពេលនោះ មានសេវាផ្នែកជំងឺអេដស៍តិចបំផុតនៅក្នុងតំបន់របស់គាត់ ហើយមិនមានប្រព័ន្ធបញ្ជូនអ្នកជំងឺទៅ រកសេវាដទៃទៀតទេ ។ ជំនួយរបស់**ផែនការបន្ទាន់**បានជួយបង្កើតអោយមានការថែទាំជាបន្តសំរាប់អ្នកដែលមានមេរោគឬជំងឺអេដស៍នៅក្នុងស្រុកដែលនាងផល្លីរស់នៅ ។ ផល្លីមិនដែលបោះបង់ចោលបំណងរបស់គាត់ក្នុងការធ្វើអោយជីវិតរបស់អ្នកជំងឺអេដស៍មានន័យនោះទេ ។ ការចូលរួមរបស់ផល្លីនិងអ្នកជំងឺអេដស៍ដទៃទៀតនៅក្នុងការថែទាំជាបន្តមានសារៈសំខាន់ណាស់ដល់ដំណើរការធ្វើសមាហរណកម្ម និង លើកកំពស់គុណភាពនៃសេវាគាំទ្រ ព្យាបាលនិងថែទាំជំងឺអេដស៍ ។ នៅពេលនេះ ផល្លីគឺជាអ្នកផ្តល់យោបល់ប្រឹក្សានិងជាមិត្ត

អប់រំមិត្ត ដោយធ្វើជាគំរូល្អដល់អ្នកដទៃ ។ អត្តចរិករាក់ទាក់និងរស់រាយរបស់គាត់ជំរុញទឹកចិត្តដល់មនុស្សទាំងអស់ដែលជួបប្រាស្រ័យជាមួយគាត់ ។ ផល្លីបាននិយាយថា "ខ្ញុំគឺជាសមាជិកនៃក្រុមដែលផ្តល់ការថែទាំនិង ការព្យាបាលប្រចាំនៅមន្ទីរពេទ្យបង្អែកមោងឫស្សី ។ ខ្ញុំសំរបសំរួលការប្រជុំប្រចាំខែនៃក្រុមគាំទ្រ**មិត្តជួយមិត្ត** នៅក្នុងមន្ទីរពេទ្យ ។ ក្រៅពីនេះ ខ្ញុំរៀបចំការប្រជុំដើម្បីផ្តល់យោបល់ប្រឹក្សាជាមួយអ្នកជំងឺអេដស៍ដើម្បីអោយគេចេះប្រើថ្នាំប្រឆាំងនឹងជំងឺអេដស៍អោយបានត្រឹមត្រូវ ។ ផ្នែកសំខាន់មួយនៃការងាររបស់ខ្ញុំគឺចុះទៅដល់អ្នកជំងឺអេដស៍និងគ្រួសាររបស់គេនៅពេលគេមកសំរាកនៅមន្ទីរពេទ្យ ដើម្បីជួយគេផ្នែកស្មារតី និងផ្តល់ពតិមានស្តីពីជំងឺអេដស៍និងការថែទាំខ្លួនឯង" ។

លោកសង្ឃផ្តល់ការថែទាំផ្នែកជំងឺអេដស៍

ដោយមានជំនួយពី**ផែនការបន្ទាន់** អង្គការពុទ្ធសាសនាដើម្បីការអភិវឌ្ឍន៍កំពុងតែបំពេញចន្លោះប្រហោងរវាងសហគមន៍សាសនានិងសហគមន៍មិនមែនសាសនានៅកម្ពុជា ។ អង្គការពុទ្ធសាសនាដើម្បីការអភិវឌ្ឍន៍ផ្តល់ការថែទាំនៅតាមផ្ទះដល់អ្នកជំងឺអេដស៍និងផ្តល់សេវាដល់កុមារដែលឪពុកម្តាយស្លាប់ចោលដោយសារជំងឺអេដស៍ ។ អង្គការនេះដំណើរការ "សាលារៀនអភិវឌ្ឍន៍សន្តិភាព" ក្នុងរយៈពេល ៦ អាទិត្យដែលក្នុងនោះលោកសង្ឃរៀនសូត្រពីរបៀបផ្តល់ការថែទាំសុខភាពទាក់ទងនឹងជំងឺអេដស៍ និងសិក្សាពីវិធីសាស្ត្រផ្សព្វផ្សាយកសិកម្មនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្នុងចំណោមព្រះសង្ឃដែលបានឆ្លងកាត់សាលាអភិវឌ្ឍន៍សន្តិភាព មានច្រើនអង្គបានត្រឡប់មកភូមិកំណើតវិញហើយបានបង្កើតសមាគមអ្នកជំងឺអេដស៍ដែលផ្តល់ការថែទាំនៅតាមផ្ទះនិងសេវាការពារជំងឺអេដស៍ ។ លោកសង្ឃទាំងនេះថែមទាំងបានបង្កើតមជ្ឈមណ្ឌលនៅតាមវត្ត ដោយផ្តល់ការថែទាំនិងជំនួយដោយផ្ទាល់ដល់កុមារកំព្រានិងកុមាររងាយរងគ្រោះ ហើយខិតខំធ្វើយ៉ាងណាអោយក្មេងទាំងនេះបានចូលសាលារៀន ។